# មាតិកា

**អារម្ភកថា** .......... i

**ផ្នែកទី ១ : និយមន័យ គោលបំណង និងវិសាលភាពនៃការអនុវត្តន៍**

១. និយមន័យ .......... ១

២. គោលបំណង .......... ១

៣. វិសាលភាពនៃការអនុវត្តន៍ .......... ១

**ផ្នែកទី ២ : នីតិវិធីសម្រាប់ការរៀបចំធ្វើបាតុកម្មដោយសន្តិវិធី** .......... ២

១. នីតិវិធីសម្រាប់អ្នកដឹកនាំបាតុកម្ម .......... ២

២. នីតិវិធីនៃការជូនដំណឹង .......... ៣

៣. កន្លែងបញ្ចេញមតិជាសាធារណៈ .......... ៥

**ផ្នែកទី ៣ : ការទទួលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច និងអ្នកដឹកនាំបាតុកម្ម** .......... ៦

១. កាតព្វកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ចដែលទទួលបានការជូនដំណឹងអំពីការធ្វើបាតុកម្មដោយសន្តិវិធី .......... ៦

២. កាតព្វកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងករណីមានព័ត៌មានច្បាស់លាស់ចង្អុលបង្ហាញថាបាតុកម្មអាចនឹងបណ្តាលឲ្យមានគ្រោះថ្នាក់ ឬ អាចនឹងប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ .......... ៧

៣. កាតព្វកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ចអំឡុងពេលបាតុកម្ម .......... ៩

៤. កាតព្វកិច្ចរបស់អ្នកដឹកនាំបាតុកម្មដោយសន្តិវិធី .......... ១១

**ផ្នែកទី ៤ : នីតិវិធីដោះស្រាយបទល្មើស និងទោសប្បញ្ញត្តិ** .......... ១២

១. កាតព្វកិច្ចរបស់មន្ត្រីមូលដ្ឋានក្នុងករណីមានអ្នកគំរាមកំហែងឆាវឆៅបង្អាក់ដល់ការធ្វើបាតុកម្មដោយសន្តិវិធី និងក្នុងករណីបាតុកម្មដោយសន្តិវិធីបង្កជាអំពើហឹង្សា .......... ១២

## អារម្ភកថា

រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា បានខិតខំបំពេញនិងបង្កើតសមិទ្ធផលជាច្រើន គួរឱ្យកត់សំគាល់ទាំងក្នុងក្របខ័ណ្ឌជាតិនិងអន្តរជាតិ។ទន្ទឹមនឹងនេះ ការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋក៏កំពុងត្រូវបានយកចិត្តទុកដាក់យ៉ាងហ្មត់ចត់ផងដែរ តាមរយៈការរៀបចំសេចក្តីព្រាង និងការអនុម័តច្បាប់នានា សំដៅធានាការអនុវត្តសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ ស្របតាមការរីកចម្រើនរបស់ប្រទេសជាតិក្នុងកាលៈទេសៈបច្ចុប្បន្ន។

អនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី៤ នៃរដ្ឋសភា ក្រសួងមហាផ្ទៃ បានសហការយ៉ាងជិតស្និទ្ធជាមួយសង្គមស៊ីវិល ក្នុងការកសាងសេចក្តីព្រាងច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីត្រូវបានរដ្ឋសភាអនុម័ត និងព្រឹទ្ធសភាយល់ព្រម និងឡាយព្រះហស្តលេខាប្រកាសឱ្យប្រើដោយព្រះមហាក្សត្រ តាមរយៈព្រះរាជក្រមលេខ នស/រកម/១២០៩/០២៥ ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៩។ ច្បាប់នេះជំនួសច្បាប់ស្តីពីបាតុកម្មដែលបានប្រកាសឱ្យប្រើដោយក្រឹត្យលេខ ១១៥ ក្រ ចុះថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជា។

ច្បាប់នេះ មានគោលបំណងការពារការធ្វើបាតុកម្មដោយសន្តិវិធី ដោយផ្សារភ្ជាប់នឹងការការពារដល់សិទ្ធិទាំងឡាយរបស់ប្រជាពលរដ្ឋដទៃទៀត។

សិទ្ធិធ្វើបាតុកម្មដោយសន្តិវិធី គឺជាសិទ្ធិមួយ ដែលទទួលស្គាល់ដោយមាត្រា៤១ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន ។ សិទ្ធិធ្វើបាតុកម្មដោយសន្តិវិធីជាមូលដ្ឋានគ្រឹះមួយ នៃលទ្ធិប្រជាធិបតេយ្យ ពីព្រោះសិទ្ធិនេះ ត្រូវផ្សារភ្ជាប់ទៅនឹងសេរីភាពខាងការបញ្ចេញមតិ ។ ស្របពេលជាមួយគ្នានេះ អ្នកទាំងឡាយដែលអនុវត្តសិទ្ធិ សេរីភាពក្នុងការធ្វើបាតុកម្មដោយសន្តិវិធីត្រូវគោរពទៅតាមបញ្ញត្តិច្បាប់ពោលគឺធ្វើយ៉ាងណាកុំឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់អ្នកដទៃ ឬ ធ្វើឱ្យប៉ះពាល់ដល់សន្តិសុខជាតិ សុវត្ថិភាព ឬសណ្តាប់ធ្នាប់សាធារណៈ។

ក្នុងការអនុវត្តច្បាប់នេះ អាជ្ញាធរអនុវត្តច្បាប់ មានភារកិច្ចប្រកាន់ខ្ជាប់នូវគោលការណ៍ណែនាំ ដូចតទៅៈ

-ច្បាប់នេះជាច្បាប់ដែលផ្តល់លទ្ធភាពនិងធានាថាការធ្វើបាតុកម្មអាចប្រព្រឹត្តទៅបានដោយសន្តិវិធី។ ដូច្នេះ អាជ្ញាធរអនុវត្តច្បាប់នៅថ្នាក់រាជធានី និងខេត្តគួរយល់ព្រមឱ្យមានការធ្វើបាតុកម្ម

ដោយសន្តិវិធី លើកលែងតែមានការគំរាមកំហែងជាក់លាក់ និងពិតប្រាកដចំពោះសន្តិសុខជាតិ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។

-ការរិតត្បិតណាមួយ ដែលត្រូវអនុវត្តចំពោះការធ្វើបាតុកម្មទាំងឡាយ គួរធ្វើឡើងក្នុងលក្ខណៈសមស្រប។ អាជ្ញាធរគួរបង្ហាញនូវភាពអត់ធ្មត់មិនប្រើកំលាំងប្រឆាំងនឹងបាតុករហើយគួរបង្កើតឱ្យមានបរិយាកាសងាយស្រួលក្នុងការធ្វើបាតុកម្មដោយសន្តិវិធី។

-ច្បាប់នេះត្រូវអនុវត្តស្មើៗគ្នាលើគ្រប់បុគ្គលទាំងអស់ និងក្នុងលក្ខណៈលុបបំបាត់ការរើសអើងផ្សេងៗ។ សិទ្ធិធ្វើបាតុកម្មដោយសន្តិវិធី គឺជាសិទ្ធិដែលមនុស្សទាំងអស់គួរទទួលបានដោយក្តីរីករាយ ដោយមិនប្រកាន់ពូជសាសន៍ ភេទ ទស្សនៈនយោបាយ ឬហេតុផលផ្សេងទៀត។

-អាជ្ញាធរទាំងឡាយ ត្រូវមានលក្ខណៈទន់ភ្លន់ចំពោះការធ្វើបាតុកម្ម ។ ក្នុងការអនុវត្តច្បាប់នេះ អាជ្ញាធរ អ្នករៀបចំបាតុកម្ម និងបាតុករទាំងឡាយត្រូវសហការធ្វើការរួមគ្នាដើម្បីធានាថាបាតុកម្មអាចប្រព្រឹត្តទៅបានប្រកបដោយសន្តិវិធី។

ច្បាប់ថ្មីនេះនឹងជួយប្រជាពលរដ្ឋ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ក្នុងការការពារសិទ្ធិធ្វើបាតុកម្មដោយសន្តិវិធី ហើយនឹងធានាថាអាជ្ញាធររាជធានី/ខេត្ត នឹងទទួលខុសត្រូវក្នុងការអនុវត្តច្បាប់នេះ។

ក្រសួងមហាផ្ទៃ រួមជាមួយនឹងសង្គមស៊ីវិល បានរៀបរៀងសេចក្តីណែនាំស្តីពីនីតិវិធីទាំងឡាយទាក់ទងនឹងការអនុវត្តច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធីនេះ ក្នុងគោលដៅផ្តល់នូវការណែនាំដល់អ្នកទាំងឡាយដែលយកច្បាប់នេះទៅប្រើប្រាស់។

សៀវភៅណែនាំអនុវត្តន៍ច្បាប់នេះ នឹងបរិយាយអំពីគោលការណ៍ណែនាំមួយចំនួនដើម្បីជួយសម្រួលទាំងប្រជាពលរដ្ឋទាំងអាជ្ញាធរឱ្យប្រតិបត្តិស្របទៅតាមច្បាប់។

ក្រសួងមហាផ្ទៃ សង្ឃឹមថា អាជ្ញាធររាជធានី និងខេត្តទាំងអស់ នឹងយកអស់ស្មារតីទទួលខុសត្រូវអនុវត្តច្បាប់នេះឱ្យបានសមស្របតាមបំណងប្រាថ្នារបស់ប្រជាពលរដ្ឋយើង។

## ផ្នែកទី ១ : និយមន័យ គោលបំណង និងវិសាលភាពអនុវត្តន៍

### ១. <u>និយមន័យ</u>

ពាក្យ"បាតុកម្មដោយសន្តិវិធី "សំដៅលើការប្រមូលផ្តុំគ្នា ឬការដង្ហែក្បួន ដោយមនុស្សមួយក្រុមដើម្បីទាមទារ តវ៉ា ឬសម្តែងជាសាធារណៈនូវមនោសញ្ចេតនា គំនិត ឬឆន្ទៈរបស់ក្រុមខ្លួន ដោយសន្តិវិធី តាមរូបភាព ឬមធ្យោបាយផ្សេងៗ ។ (មាត្រា៤)

### ២. <u>គោលបំណង</u>

២-១. ច្បាប់នេះមានគោលបំណងធានាការពារសេរីភាពខាងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប តាមរយៈការធ្វើបាតុកម្មដោយសន្តិវិធី ប៉ុន្តែមិនត្រូវឆ្លៀតប្រើសិទ្ធិនេះដោយ រំលោភនាំឱ្យប៉ះពាល់សិទ្ធិសេរីភាពនិងកិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទំលាប់ល្អរបស់ សង្គមជាតិ ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិឡើយ។ (មាត្រា ២)

២-២. ***ចំណុចបំភ្លឺ៖***

***២-២-១.*** *មាត្រា២ ចង្អុលបង្ហាញថា ច្បាប់នេះផ្តល់លទ្ធភាពដល់ជនទាំងអស់ ក្នុងការធ្វើបាតុកម្មដោយសន្តិវិធី។*

***២-២-២.*** *ការរិតត្បិតទៅលើការធ្វើបាតុកម្ម អាចធ្វើបាន ក្នុងករណីមានផលប៉ះពាល់ដល់សន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ និងដល់សិទ្ធិ និងសេរីភាពរបស់អ្នកដទៃប៉ុណ្ណោះ ។*

***២-២-៣.*** *អ្នកចូលរួមបាតុកម្ម មិនត្រូវធ្វើឲ្យប៉ះពាល់ដោយមិនត្រឹមត្រូវដល់សិទ្ធិទាំងឡាយរបស់អ្នកដែលមិនចូលរួមបាតុកម្មឡើយ ។*

### ៣. <u>វិសាលភាពនៃការអនុវត្ត</u>

៣-១. ច្បាប់នេះ មានវិសាលភាពអនុវត្តលើរាល់ការប្រមូលផ្តុំគ្នា ឬការដង្ហែក្បួនដោយសន្តិវិធីទាំងអស់ <u>លើកលែងតែ៖</u>

៣-១-១. ការប្រមូលផ្តុំគ្នា អំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោតណាមួយ។

៣-១-២. ការប្រមូលផ្តុំទាក់ទងនឹងវិវាទការងារ និងដែលធ្វើឡើងនៅខាងក្នុង និងខាងក្រៅ អែបប្របរបងរោងចក្រ ឬ សហគ្រាស ឬ ស្ថាប័ននានា។

៣-១-៣. ការដើរហែក្បួនព្យុហយាត្រា ដើរហែសព និងការប្រមូលផ្តុំគ្នាដទៃទៀត ក្នុងគោលបំណងបម្រើសាសនា សិល្បៈ វប្បធម៌ ទំនៀមទម្លាប់ ប្រពៃណីជាតិ ឬសកម្មភាពផ្សព្វផ្សាយអប់រំ ដើម្បីផលប្រយោជន៍សង្គម។ (មាត្រា៣)

៣-២. ***ចំណុចបំភ្លឺ ៖***

*៣-២-១. ឧទាហរណ៍អំពី "ការប្រមូលផ្តុំ" ដែលមិនគ្របដណ្តប់ដោយច្បាប់នេះ៖*

*ក. មនុស្សជួបជុំគ្នា ក្នុងគោលដៅមិនមែនធ្វើការតវ៉ាជាលក្ខណៈសាធារណៈ។*

*ខ. ការជួបប្រជុំនានា ដើម្បីពិភាក្សារិះរកវិធីដោះស្រាយបញ្ហាផ្សេងៗ*

*គ. សកម្មភាពផ្សព្វផ្សាយអប់រំផ្សេងៗ រាប់បញ្ចូលទាំង៖*

- *ការបណ្តុះបណ្តាល*
- *សិក្ខាសាលា*
- *វេទិកាសាធារណៈ*
- *សន្និសីទសារព័ត៌មាន។*

*ឃ. កូដកម្ម និងការបោះឆ្នោតសហជីព*

*ង. ការប្រមូលផ្តុំធ្វើកូដកម្មស្ថិតនៅខាងក្រៅរោងចក្រក្នុងចម្ងាយសមស្រប។*

## ផ្នែកទី ២ : នីតិវិធីសម្រាប់ការរៀបចំធ្វើបាតុកម្មដោយសន្តិវិធី

### ១- <u>នីតិវិធីសម្រាប់អ្នកដឹកនាំធ្វើបាតុកម្ម</u>

១-១. បុគ្គលទាំងឡាយណា ដែលមានបំណងរៀបចំធ្វើបាតុកម្មដោយសន្តិវិធីនៅទីកន្លែងសាធារណៈណាមួយ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរដែនដីរាជធានី ឬខេត្ត មានសមត្ថកិច្ចគ្រប់គ្រងទីកន្លែងនោះ។ ( មាត្រា ៥)

១-២. លិខិតជូនដំណឹងត្រូវផ្តល់ព័ត៌មានដូចខាងក្រោម៖

១-២-១. នាមត្រកូល នាមខ្លួន និងអាសយដ្ឋានអចិន្ត្រៃយ៍ សម្រាប់ទំនាក់ទំនងរបស់អ្នកដឹកនាំចំនួនបី (៣)នាក់ ដោយភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរថតចម្លង។

១-២-២. គោលបំណងនៃការធ្វើបាតុកម្ម។

១-២-៣. កាលបរិច្ឆេទ ពេលវេលា និងរយៈពេល នៃការធ្វើបាតុកម្ម ទីកន្លែង និងផ្លូវដែលត្រូវប្រើប្រាស់ក្នុងការធ្វើបាតុកម្ម ចំនួនអ្នកចូលរួមដែលបានគ្រោងទុក ព្រមទាំងចំនួន និងប្រភេទនៃយានជំនិះនីមួយៗ។ (មាត្រា៦)

១-៣. ***ចំណុចបំភ្លឺ***

*១-៣-១. បាតុកម្មអាចរៀបចំឡើងចំពោះគ្រប់បញ្ហាដែលច្បាប់អនុញ្ញាត។*

*១-៣-២. មិនមានការដាក់កម្រិតណាមួយទៅលើចំនួនមនុស្ស ដែលអាចចូលរួមក្នុងបាតុកម្មជាទូទៅឡើយ។*

*១-៣-៣. បាតុកម្មមួយ គួរត្រូវបានអនុញ្ញាតឱ្យធ្វើបន្ត បើទោះបីជាអ្នកដឹកនាំបាតុកម្មប៉ាន់ប្រមាណខុសនូវចំនួនអ្នកចូលរួម ឬ ចំនួនប្រភេទយានជំនិះនីមួយៗ តិចជាងចំនួនចូលរួមពិតប្រាកដក៏ដោយ លើកលែងតែចំនួនប៉ាន់ស្មាននោះខុសគ្នាច្រើនបើប្រៀបធៀបទៅនឹងចំនួនពិតប្រាកដ ដែលចូលរួមក្នុងបាតុកម្ម ហើយការធ្វើបាតុកម្មនេះ គំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈ។*

*១-៣-៤. លិខិតជូនដំណឹង មិនចាំបាច់បង្ហាញឲ្យដឹងថាតើបាតុករនឹងធ្វើដំណើរតាមមធ្យោបាយណានោះទេ មកកាន់កន្លែងធ្វើបាតុកម្ម ។*

## ២.<u>នីតិវិធីនៃការជូនដំណឹង</u>

២-១. ប្រសិនបើ ការធ្វើបាតុកម្ម មិនត្រូវបានរៀបចំឡើងនៅកន្លែងបញ្ចេញមតិជាសាធារណៈ ឬ នៅកន្លែងដែលជាទ្រព្យសម្បត្តិឯកជន ឬជាទ្រព្យសម្បត្តិសមូហភាព លិខិតជូនដំណឹងត្រូវដាក់ទៅសាលារាជធានី ឬសាលាខេត្ត យ៉ាងហោចណាស់ ប្រាំ (៥)ថ្ងៃ នៃថ្ងៃធ្វើការងារ មុនពេលកំណត់ នៃការធ្វើបាតុកម្ម។ (មាត្រា៧)

២-២. ប្រសិនបើការធ្វើបាតុកម្មនោះ នឹងត្រូវធ្វើឡើងនៅកន្លែងបញ្ចេញមតិជាសាធារណៈ ឬ នៅកន្លែងដែលជាទ្រព្យសម្បត្តិឯកជន ឬជាទ្រព្យសម្បត្តិសមូហភាព លិខិតជូនដំណឹងត្រូវដាក់ជូនអាជ្ញាធរដែនដីរាជធានី ឬខេត្តមានសមត្ថកិច្ចយ៉ាងហោចណាស់ឱ្យបានមុន ដប់ពីរ (១២) ម៉ោងក្នុងថ្ងៃការងារ ឬ មុនសាមសិបប្រាំមួយ (៣៦) ម៉ោង ក្នុងថ្ងៃឈប់សម្រាក ។ ទោះយ៉ាងណាក៏ដោយ ចំនួនមនុស្សច្រើនបំផុត ដែលអាចធ្វើបាតុកម្មនៅកន្លែងបញ្ចេញមតិជាសាធារណៈគឺត្រឹម ពីររយ (២០០) នាក់ ប៉ុណ្ណោះ។ (មាត្រា១៨)

២-៣. ប្រសិនបើមានក្រុមពីរ ឬច្រើនជាងនេះ មានបំណងរៀបចំបាតុកម្មនៅចំពេល និងកន្លែងតែមួយ អាជ្ញាធរដែនដីមានសមត្ថកិច្ច ត្រូវសម្រេចឱ្យក្រុមអ្នកដែលបានដាក់លិខិតជូនដំណឹងមុន ទទួលបានសិទ្ធិធ្វើមុន។ ឬមួយក៏អាជ្ញាធរអាចអនុញ្ញាតឲ្យក្រុមមួយទៀត រៀបចំធ្វើបាតុកម្មនៅកន្លែងមួយផ្សេងទៀត ដែលមានចម្ងាយយ៉ាងតិច ៥០០ ម៉ែត្រពីគ្នា។ ( មាត្រា ១៤)

២-៤. ***ចំណុចបំភ្លឺ៖***

*២-៤-១.* *ប្រសិនបើការឆ្លើយតបចំពោះលិខិតជូនដំណឹង ពុំត្រូវបានទទួលពីអាជ្ញាធរមានសមត្ថកិច្ចទេ នោះបាតុកម្មអាចប្រព្រឹត្តទៅបានដោយគ្មានការបំបែកឡើយ។*

*២-៤-២.* *សាលារាជធានី ឬខេត្ត គឺជា " អាជ្ញាធរដែនដីមានសមត្ថកិច្ច" ដែលត្រូវជូនដំណឹង ដោយមិនគិតថា បាតុកម្មនោះរៀបចំនៅកន្លែងណាឡើយ។*

*២-៤-៣.* *លិខិតជូនដំណឹងធ្វើបាតុកម្មនៅកន្លែងបញ្ចេញមតិជាសាធារណៈ ឬ នៅកន្លែងដែលជាទ្រព្យសម្បត្តិឯកជន ឬជាទ្រព្យសម្បត្តិសម្ងហភាព តម្រូវឱ្យមានត្រឹមតែហត្ថលេខាឬស្នាមមេដៃរបស់អ្នកដឹកនាំបាតុកម្មបីនាក់ និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរថតចម្លងប៉ុណ្ណោះ។*

*២-៤-៤.* *ប្រសិនបើបាតុកម្មត្រូវធ្វើនៅកន្លែងបញ្ចេញមតិជាសាធារណៈ ហើយមានមនុស្សលើសពីចំនួន ២០០ នាក់ បន្តិចបន្តួចបានចូលរួម អាជ្ញាធរគួរតែអនុញ្ញាតឱ្យបាតុកម្មបន្តធ្វើទៅបាន ប្រសិនបើបាតុកម្មនោះ មិនមានការគម្រាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈ។*

*២-៤-៥.* *អាជ្ញាធរ គួរខិតខំឲ្យអស់លទ្ធភាពតាមតែអាចធ្វើបាន ដើម្បីធានាថា ក្រុមទាំងអស់ដែលចង់ធ្វើបាតុកម្ម អាចរៀបចំបាតុកម្មស្របទៅតាមបែបបទ ពេលវេលា និងទីកន្លែងដែលបានស្នើសុំ។*

*២-៤-៦.* *អង្គការមិនមែនរដ្ឋាភិបាល អាចរៀបចំបាតុកម្មនៅកន្លែងទ្រព្យសម្បត្តិឯកជនរបស់ខ្លួនបាន។*

## ៣-<u>កន្លែងបញ្ចេញមតិជាសាធារណៈ</u>

៣-១. កន្លែងបញ្ចេញមតិជាសាធារណៈគឺជាកន្លែងសម្រាប់រៀបចំធ្វើបាតុកម្មដោយសន្តិវិធី ឬ សម្រាប់បញ្ចេញមតិជាសាធារណៈ។ រាជធានីនិងខេត្តនីមួយៗត្រូវបង្កើតឱ្យមានកន្លែងបញ្ចេញមតិជាសាធារណៈឱ្យបានត្រឹមថ្ងៃ ទី ៦ ខែ មិថុនា ឆ្នាំ ២០១០។ កន្លែងបញ្ចេញមតិជាសាធារណៈត្រូវតែជាបរិវេណ ឬ មជ្ឈមណ្ឌល ដែលសាធារណជនទូទៅងាយស្ដាប់ឮ និង មើលឃើញ។ (មាត្រា២៨)

៣-២. ការធ្វើបាតុកម្មនៅកន្លែងបញ្ចេញមតិជាសាធារណៈត្រូវធ្វើឡើងចន្លោះពេលពីម៉ោង ៦ ព្រឹក ដល់ម៉ោង ៦ ល្ងាច។ (មាត្រា១៤)

៣-៣. ***ចំណុចបំភ្លឺ ៖***

៣-៣-១. *កន្លែងបញ្ចេញមតិជាសាធារណៈគួរស្ថិតក្នុងទីប្រជុំជនរាជធានី ឬខេត្ត។ កន្លែងបញ្ចេញមតិជាសាធារ-ណៈនេះ មិនគួរស្ថិតនៅកន្លែងមួយដែលស្ងាត់ជ្រងំនោះទេ។ បាតុករមានសិទ្ធិឲ្យគេដឹងឮនូវការទាមទាររបស់ខ្លួន។*

*៣-៣-២. បាតុកម្មនៅកន្លែងបញ្ចេញមតិជាសាធារណៈ ឬកន្លែងទ្រព្យសម្បត្តិឯកជន ត្រូវបានកម្រិតត្រឹមតែចំនួន ២០០ នាក់ប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាក៏ដោយ អាជ្ញាធរគួរតែពិចារណានិងថ្លឹងថ្លែងទៅលើការអនុវត្តច្បាប់នេះតាមស្ថានភាពជាក់ស្ដែង។ ទោះបីជាច្បាប់កំណត់ចំនួនអ្នកចូលរួមត្រឹម ២០០នាក់ សម្រាប់បាតុកម្មនៅកន្លែងបញ្ចេញមតិជាសាធារណៈ ឬនៅកន្លែងទ្រព្យសម្បត្តិឯកជនក៏ដោយ ក៏អាជ្ញាធរអាចប្រកាន់ជំហរទន់ភ្លន់ ប្រសិនបើការធ្វើបាតុកម្មនោះមិនបង្កឲ្យកើតមានចលាចលជាសាធារណៈនោះទេ។*

## ផ្នែកទី ៣ : ការទទួលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច និង អ្នកដឹកនាំធ្វើបាតុកម្ម

### ១-កាតព្វកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ចដែលទទួលបានការជូនដំណឹងអំពីការធ្វើបាតុកម្មដោយសន្តិវិធី

១-១. នៅពេលទទួលបានលិខិតជូនដំណឹងហើយ សាលារាជធានី ឬសាលាខេត្ត ត្រូវ៖

១-១-១. ចេញបង្កាន់ដៃទទួលស្គាល់ជាលាយលក្ខណ៍អក្សរ ជូនអ្នកដែលបានដាក់លិខិតជូនដំណឹង។

១-១-២. ផ្សព្វផ្សាយលិខិតជូនដំណឹងនេះជាបន្ទាន់ នៅទីកន្លែងណាមួយដែលងាយមើលឃើញក្នុងអគាររដ្ឋបាល ឬ នៅលើគេហទំព័រផ្លូវការរបស់ខ្លួន។

១-១-៣. បញ្ជូនច្បាប់ថតចម្លង នៃលិខិតជូនដំណឹងនេះ ទៅស្នាក់ការនគរបាលមូលដ្ឋាន ស្នាក់ការកងរាជអាវុធហត្ថ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដទៃទៀត។ (មាត្រា៨)

១-២. អាជ្ញាធរដែនដីរាជធានី ឬខេត្ត មានសមត្ថកិច្ច ត្រូវឆ្លើយតបជាវិជ្ជមានចំពោះលិខិតជូនដំណឹងនោះជាលាយលក្ខណ៍អក្សរ លើកលែងតែ៖

១-២-១. ការធ្វើបាតុកម្មដោយសន្តិវិធីត្រូវចំលើថ្ងៃប្រារព្ធព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រ ព្រះរាជពិធីរាជាភិសេកព្រះមហាក្សត្រ ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក ពិធីបុណ្យឯករាជ្យជាតិ ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឬ ពិធីបុណ្យភ្ជុំបិណ្ឌ។ ឬ

១-២-២. មានព័ត៌មានច្បាស់ថាការធ្វើបាតុកម្មនេះនឹងអាចបង្កគ្រោះថ្នាក់ណាមួយ ឬ អាចនឹងប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។ (មាត្រា៩)

១-៣. ការឆ្លើយតបរបស់អាជ្ញាធរ ត្រូវធ្វើឡើងក្នុងរយៈពេល បី (៣) ថ្ងៃ នៃថ្ងៃការងារដោយគិតចាប់ពីថ្ងៃដែលលិខិតជូនដំណឹងត្រូវបានដាក់ជូន។ ប្រសិនបើអាជ្ញាធរខកខានមិនបានឆ្លើយតបរហូតដល់ពេលកំណត់ដែលនឹងត្រូវធ្វើបាតុកម្មដោយសន្តិវិធី នោះមានន័យថា អាជ្ញាធរបានព្រមព្រៀងហើយ។ (មាត្រា១០)

១-៤. *ចំណុចបំភ្លឺ*

១-៤-១. *អ្នកដែលបានដាក់លិខិតជូនដំណឹងត្រឹមត្រូវដល់អាជ្ញាធរនឹងមានសិទ្ធិក្នុងការធ្វើបាតុកម្មដូចមានចែងក្នុងលិខិតជូនដំណឹង លើកលែងតែករណីដែលអាជ្ញាធរបានជូនដំណឹងពួកគេអំពីតម្រូវការនៃការដាក់កម្រិតផ្សេងៗ។*

១-៤-២. *ត្រូវចាត់ទុកថាមានការព្រមព្រៀង ប្រសិនបើអាជ្ញាធរដែនដីរាជធានី ឬខេត្ត ខកខានមិនបានឆ្លើយតបទៅនឹងលិខិតជូនដំណឹងធ្វើបាតុកម្មក្នុងរយៈពេល បី(៣) ថ្ងៃនៃថ្ងៃការងារ។*

១-៤-៣. *ថ្ងៃឈប់សម្រាកផ្លូវការរបស់រាជរដ្ឋាភិបាល មិនត្រូវបានរាប់បញ្ចូលជាផ្នែកមួយនៃរយៈពេលដែលអាជ្ញាធរមានសមត្ថកិច្ចត្រូវឆ្លើយតបចំពោះលិខិតជូនដំណឹងនោះទេ។*

១-៤-៤. *ច្បាប់នេះត្រូវបានរៀបចំឡើង ដើម្បីជួយដល់ពលរដ្ឋ និងអាជ្ញាធរទាំងឡាយក្នុងការការពារដល់សិទ្ធិជួបប្រជុំដោយសន្តិវិធី និងដើម្បីធានាថា អាជ្ញាធររាជធានី និងខេត្តទទួលខុសត្រូវចំពោះការអនុវត្តច្បាប់នេះ។*

២- <u>កាតព្វកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងករណីមាន «ព័ត៌មានច្បាស់ចង្អុលបង្ហាញថាបាតុកម្មអាចនឹងបណ្តាលឲ្យមានគ្រោះថ្នាក់ ឬ នឹងអាចប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ»</u>

២-១. ក្នុងករណីអាជ្ញាធរដែនដីមានសមត្ថកិច្ចរាជធានី ឬខេត្ត មានព័ត៌មានច្បាស់បង្ហាញថាបាតុកម្មអាចនឹងបណ្តាលឲ្យមានគ្រោះថ្នាក់ ឬ ប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ អាជ្ញាធររាជធានី ឬខេត្ត ត្រូវជូនដំណឹងដំណឹងជាបន្ទាន់ដល់អ្នកដឹកនាំបាតុកម្ម ដើម្បីឲ្យពួកគេមានពេលវេលាជួបជាមួយអាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរពាក់ព័ន្ធដទៃទៀតក្នុងការពិភាក្សារកដំណោះស្រាយ។ (មាត្រា ១១)

២-២. បើអ្នកដឹកនាំធ្វើបាតុកម្មនិងអាជ្ញាធរមូលដ្ឋាននៅតែមិនព្រមព្រៀងគ្នា នោះអាជ្ញាធររាជធានី-ខេត្តត្រូវស្នើសុំយោបល់សម្រេចពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ (មាត្រា១២)

២-៣. សេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវផ្តល់ជូនដល់អ្នកដឹកនាំធ្វើបាតុកម្មវិញក្នុងរយៈពេលយ៉ាងយូរម្ភៃបួន (២៤) ម៉ោង មុនពេលកំណត់ នៃការចាប់ផ្តើមធ្វើបាតុកម្មដោយសន្តិវិធី។

ឯកសារថតចម្លង នៃការសម្រេចរួមទាំងព័ត៌មានលម្អិត នៃការកែប្រែ ដែលបានព្រមព្រៀងគ្នាត្រូវផ្តល់ជូនទៅអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ និងជូនទៅអាជ្ញាធរដទៃទៀត ដែលមានតំបន់អាចនឹងទទួលរងនូវការប៉ះពាល់ដោយសារការធ្វើបាតុកម្មដោយសន្តិវិធីនេះ។ (មាត្រា១៣)

**២-៤. *ចំណុចបំភ្លឺ៖***

***២-៤-១.*** *ប្រសិនបើអាជ្ញាធរដែនដីរាជធានី ឬខេត្ត ជឿជាក់ថាមាន "ព័ត៌មានច្បាស់បង្ហាញថា ការធ្វើបាតុកម្មមួយអាចបង្កគ្រោះថ្នាក់ ឬអាចប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ" អាជ្ញាធរត្រូវ ៖*

*ក. ពិចារណា និងវាយតម្លៃព័ត៌មាននោះ ដើម្បីកំណត់ថាតើមានមូលដ្ឋានច្បាស់លាស់ដែរ ឬទេ និង*

*ខ. ជូនដំណឹង និងសហការជាមួយអ្នកដឹកនាំបាតុកម្ម ដើម្បីរិះរកមធ្យោបាយលុបបំបាត់គ្រោះថ្នាក់ចម្បងៗ ដើម្បីឲ្យបាតុកម្មអាចដំណើរការបាន។*

***២-៤- ២.*** *អាជ្ញាធរ ត្រូវធ្វើការវាយតម្លៃឱ្យបានគ្រប់ជ្រុងជ្រោយទៅលើព័ត៌មានដែលទទួលបានហើយមិនត្រូវចេះតែយល់ស្របនោះទេ។ អាជ្ញាធរអាចសម្រេចថាព័ត៌មាននេះ មិនបានបង្ហាញឱ្យឃើញច្បាស់ពីការអាចកើតមានគ្រោះថ្នាក់ ហើយដូច្នេះត្រូវបដិសេធព័ត៌មាននេះចោល។ ប្រសិនបើមានព័ត៌មានច្បាស់ថាការធ្វើបាតុកម្មអាចបង្កគ្រោះថ្នាក់ នោះអ្នកដឹកនាំធ្វើបាតុកម្មនិងអាជ្ញាធរមានរយៈពេល ៣ ថ្ងៃក្នុងការស្វែងរកការព្រមព្រៀងគ្នា។*

***២-៤-៣.*** *ពាក្យចចាមអារ៉ាម ការសង្ស័យ ដែលមិនមាន មូលដ្ឋានពិតប្រាកដ និងព័ត៌មានមិនជាក់លាក់ដទៃទៀតមិនអាចចាត់ទុកថាជា "ព័ត៌មានច្បាស់ដែលបញ្ជាក់ថាបាតុកម្មនោះ អាចបង្កគ្រោះថ្នាក់ ឬ អាចប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ" ឡើយ។ ប្រសិនបើមិនមាន "ព័ត៌មានច្បាស់" ទេនោះ បាតុកម្មត្រូវតែបានអនុញ្ញាតឱ្យធ្វើ។*

***២-៤-៤.*** *បាតុកម្មតវ៉ាជំទាស់ ឬគាំទ្រគោលនយោបាយ ឬសេចក្តីសម្រេចជាក់លាក់ណាមួយរបស់រដ្ឋាភិបាល មិនមែនសុទ្ធតែជាការ "បង្កគ្រោះថ្នាក់ ឬ ប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធាណៈ" ទេ។*

*២-៤-៥.* *ហានិភ័យដែលថាការធ្វើបាតុកម្មមួយនឹងបណ្តាលឱ្យមានការកកស្ទះចរាចរ មិនមែនសុទ្ធតែជាការ "បង្កគ្រោះថ្នាក់ ឬប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ" ទេ។*

*២-៤-៦.* *អាជ្ញាធរ និងអ្នកដឹកនាំធ្វើបាតុកម្ម គួរជួបប្រជុំជាបន្ទាន់ដើម្បីពិភាក្សាគ្នារកដំណោះស្រាយ និងរកមធ្យោបាយសហការសមស្របផ្សេងៗដើម្បីឱ្យបាតុកម្មអាចប្រព្រឹត្តទៅបាន។ អាជ្ញាធរនិងអ្នកដឹកនាំធ្វើបាតុកម្មត្រូវខិតខំស្វះស្វែងរកឱ្យបាននូវដំណោះស្រាយរួមមួយ។*

*២-៤-៧.* *ប្រសិនបើអាជ្ញាធរដែនដីរាជធានី ឬខេត្ត និងអ្នកដឹកនាំធ្វើបាតុកម្ម មិនអាចរកដំណោះស្រាយផ្សេងៗ ដើម្បីលុបបំបាត់គ្រោះថ្នាក់ដែលអាចកើតមានឡើងទេ អាជ្ញាធររាជធានី ឬខេត្ត ត្រូវស្នើសុំយោបល់សម្រេចពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ នៅពេលស្នើសុំយោបល់ អាជ្ញាធររាជធានី ឬខេត្ត គួរផ្តល់នូវព័ត៌មានដែលបង្អួលបង្ហាញថា បាតុកម្មនោះ អាចនឹងបង្កគ្រោះថ្នាក់ ឬ អាចប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ដំណោះស្រាយដែលខ្លួនស្នើឡើង និងដំណោះស្រាយដែលអ្នកដឹកនាំបាតុកម្មស្នើឡើង។*

## ៣. <u>កាតព្វកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ចអំឡុងពេលបាតុកម្ម</u>

៣-១. ប្រសិនបើការធ្វើបាតុកម្មនឹងមានការហែក្បួនលើផ្លូវសាធារណៈ មន្ត្រីមូលដ្ឋានត្រូវសហការជាមួយមន្ត្រីនគរបាលនិងមន្ត្រីកងរាជអាវុធហត្ថដើម្បីធ្វើការកំណត់ផ្លូវសមស្របក្នុងការបញ្ចៀសកុំឱ្យមានការរំខានធ្ងន់ធ្ងរដល់ដំណើរការអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម ឬសកម្មភាពជំនួញផ្សេងៗ។ (មាត្រា ១៥)

៣-២. អាជ្ញាធរ ត្រូវចាត់វិធានការការពារដល់ក្បួនបាតុកម្ម ហើយមិនត្រូវជ្រៀតជ្រែកដល់ការប្រព្រឹត្តទៅ នៃការធ្វើបាតុកម្មដោយសន្តិវិធីឡើយ។ បន្ថែមលើសពីនេះទៀត ប្រសិនបើមានការស្នើសុំជំនួយពីអ្នកដឹកនាំធ្វើបាតុកម្មដោយសន្តិវិធី អាជ្ញាធរត្រូវខិតខំឆ្លើយតបដើម្បីធានាថាសិទ្ធិធ្វើបាតុកម្មដោយសន្តិវិធីនិងសេរីភាពបញ្ចេញមតិរបស់បាតុករត្រូវបានរក្សាការពារ។ (មាត្រា ១៧ - ១៨)

៣-៣. អាជ្ញាធរ ដែលត្រូវបានចាត់តាំងឱ្យរក្សាសណ្តាប់ធ្នាប់នៅកន្លែងធ្វើបាតុកម្មត្រូវស្លៀកពាក់ឯកសណ្ឋានឱ្យបានត្រឹមត្រូវ ព្រមទាំងមានស្លាកឈ្មោះ និងអត្តលេខសម្គាល់ខ្លួន។ (មាត្រា ១៩)

៣-៤. អាជ្ញាធរ ត្រូវប្រកាន់ខ្ជាប់នូវអត្តចរិតអត់ធ្មត់ដាច់ខាតចំពោះការធ្វើបាតុកម្មហើយមិនត្រូវបំបែកការធ្វើបាតុកម្ម ដែលមានការព្រមព្រៀងនោះទេ រាប់ទាំងការព្រមព្រៀងដោយជាក់លាក់ ឬការព្រមព្រៀងដោយអាជ្ញាធរមិនបានឆ្លើយតបផង។ ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីបាតុកម្មដោយសន្តិវិធីបានក្លាយជាអំពើហិង្សា អាជ្ញាធរត្រូវចាត់វិធានការសមស្រប ដើម្បីទប់ស្កាត់អំពើហិង្សា និងបញ្ឈប់បាតុកម្មនោះ។ លើសពីនេះទៅទៀត ទោះជាបាតុកម្មប្រព្រឹត្តទៅដោយសន្តិវិធីក៏ដោយ ក៏អាជ្ញាធរអាចបញ្ឈប់បាតុកម្មនោះបានដែរ ប្រសិនបើមិនបានគោរពតាមនីតិវិធីដាក់លិខិតជូនដំណឹងទេនោះ។ (មាត្រា ១៩-២០)

៣-៥. ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ចំពោះមន្ត្រីអាជ្ញាធរណា ដែលបំពានកាតព្វកិច្ចរបស់ខ្លួនដូចមានចែងក្នុងមាត្រា ១៧, ១៨ និង១៩។ (មាត្រា ២២)

៣-៦. ***ចំណុចបំភ្លឺ***

*៣-៦-១.* *អាជ្ញាធរដែនដី និងមន្ត្រីដែលត្រូវបានចាត់តាំងជាតំណាងគួរសហការជាមួយអ្នកដឹកនាំធ្វើបាតុកម្ម ក្នុងការកំណត់ផ្លូវសាធារណៈសម្រាប់ការដង្ហែក្បួន។*

*៣-៦-២.* *អាជ្ញាធរដែនដី និងមន្ត្រីដែលត្រូវបានចាត់តាំងជាតំណាងត្រូវជួយសម្រួលចរាចរដើម្បីបញ្ចៀសការរំខានដល់ដំណើរការអាជីវកម្ម។*

*៣-៦-៣.* *អាជ្ញាធរដែនដី និងមន្ត្រីដែលត្រូវបានចាត់តាំងជាតំណាងមិនត្រូវជ្រៀតជ្រែកក្នុងដំណើរការធ្វើបាតុកម្ម និង ត្រូវជួយអ្នកដឹកនាំបាតុកម្ម ប្រសិនបើពួកគេស្នើសុំជំនួយ។*

*៣-៦-៤.* *ការធ្វើបាតុកម្ម គួរត្រូវបំបែកល្គឹកណាតែគ្មានជម្រើសផ្សេងទៀតតែប៉ុណ្ណោះ។ អាជ្ញាធរដែនដី និងមន្ត្រីដែលត្រូវបានចាត់តាំងជាតំណាង គួរអត់ធ្មត់កុំធ្វើការបំបែកបាតុកម្ម បើទោះបីជាបាតុករប្រើប្រាស់ពាក្យសម្តីមិនគប្បី យ៉ាងណាក៏ដោយ ។ ជាបឋមអាជ្ញាធរគួរព្យាយាមយកអ្នកបង្កបញ្ហា ឱ្យនៅដាច់ដោយឡែក*

*និង/ឬ ព្យាយាមបញ្ឈប់អំពើហិង្សា មុនចាប់ផ្តើមបំបែកបាតុកម្ម។*

*៣-៦-៥.* *អន្តរាគមន៍របស់នគរបាលត្រូវសមមាត្រនឹងស្ថានការណ៍ ហើយត្រូវធ្វើត្រឹមតែក្នុងវិសាលភាពមួយដែលចាំបាច់ដើម្បីរៀបចំសណ្តាប់ធ្នាប់ឡើងវិញឱ្យបានឆាប់រហ័សតែប៉ុណ្ណោះ។*

*៣-៦-៦.* *ប្រការដែលសំខាន់ គឺត្រូវឃាមការពារកុំឱ្យកើតមានបាតុភាពណាមួយ ដែលនៅពេលនោះមានអ្នកខាងក្រៅព្យាយាមបង្កបញ្ហា ដើម្បីធ្វើឱ្យនគរបាលបំបែកបាតុកម្ម ឬចាប់អ្នកដឹកនាំធ្វើបាតុកម្មឱ្យទទួលខុសត្រូវចំពោះការខូចខាត ឬរបួសស្នាមនានា។*

*៣-៦-៧.* *ទោះបីជាបាតុកម្មមួយប្រព្រឹត្តទៅដោយសន្តិវិធីក៏ដោយ អាជ្ញាធរមានសមត្ថកិច្ច អាចបញ្ឈប់បាតុកម្មនោះបាន ប្រសិនបើពុំមានការជូនដំណឹងទេ។ ក្នុងករណីនេះ អាជ្ញាធរមានសមត្ថកិច្ច សម្រេចតាមស្ថានភាពជាក់ស្តែង។*

## ៤. <u>កាតព្វកិច្ចរបស់អ្នករៀបចំបាតុកម្មដោយសន្តិវិធី</u>

៤-១. សិទ្ធិធ្វើបាតុកម្មដោយសន្តិវិធី មិនត្រូវប្រើប្រាស់ដោយរំលោភនាំឲ្យប៉ះពាល់ដល់សិទ្ធិសេរីភាព និង កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទំលាប់ប្រពៃណីល្អរបស់សង្គមជាតិ ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិឡើយ។ (មាត្រា ២)

៤-២. អ្នកដឹកនាំបាតុកម្មដោយសន្តិវិធី ត្រូវទទួលខុសត្រូវក្នុងការចាត់វិធានការសមស្របផ្សេងៗ ដើម្បីឲ្យបាតុកម្មប្រព្រឹត្តទៅដោយសន្តិវិធី និង ត្រូវ៖

៤-២-១. ជម្រាបអ្នកចូលរួមបាតុកម្ម ឲ្យបានដឹងអំពីការទទួលខុសត្រូវរបស់ពួកគេ ដូចមានចែងក្នុងច្បាប់។

៤-២-២. ធ្វើការពិភាក្សា និង សហប្រតិបត្តិការជាមួយមន្ត្រីអាជ្ញាធរមូលដ្ឋាន ដើម្បីធានាថាបាតុកម្មប្រព្រឹត្តទៅដោយសន្តិវិធី និង

៤-២-៣. រៀបចំបាតុកម្មឲ្យមានរបៀបរៀបរយល្អ និង ត្រឹមត្រូវតាមពេលវេលានិងទីកន្លែងកំណត់។

៤-៣. អ្នកដឹកនាំបាតុកម្មដែលរំលោភលើកាតព្វកិច្ចរបស់ខ្លួន ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ។ (មាត្រា ២១)

៤-៤. ***ចំណុចបំភ្លឺ***

*៤-៤-១.* *ទោះបីជាអ្នកដឹកនាំធ្វើបាតុកម្ម ត្រូវបានព្រមានស្របតាមមាត្រា២១ ក៏ដោយ ក៏ការព្រមាននេះ មិនត្រូវរារាំងជាស្វ័យប្រវត្តិដល់ពួកគេក្នុងការធ្វើជាអ្នកដឹកនាំបាតុកម្មនៅពេលអនាគតឡើយ ប្រសិនបើពួកគេអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួន ដូចមានចែងក្នុងច្បាប់នេះ។*

*៤-៤-២.* *ប្រសិនបើមានអ្នកក្រៅចូលមកអុកឡុកក្នុងបាតុកម្ម ហើយបង្កជាបញ្ហាផ្សេងៗ អ្នកដឹកនាំធ្វើបាតុកម្មគួរធ្វើការស្នើសុំជាបន្ទាន់ទៅអាជ្ញាធរឱ្យយកបុគ្គលនោះចេញ។ អាជ្ញាធរគួរឆ្លើយតបតាមសំណូមពរនេះ។*

## ផ្នែកទី ៤ : នីតិវិធីដោះស្រាយបទល្មើសនិងទោសប្បញ្ញត្តិ

### ១. កាតព្វកិច្ចរបស់មន្ត្រីមូលដ្ឋានក្នុងករណីមានអ្នកគំរាមកំហែងឆានៅបង្អាក់ដល់ការធ្វើបាតុកម្មដោយសន្តិវិធី និងក្នុងករណីបាតុកម្មដោយសន្តិវិធីបង្កជាអំពើហិង្សា

១-១. អាជ្ញាធរត្រូវដកហូតឧបករណ៍ដែលកាន់ដោយបាតុករណាម្នាក់ហើយដែលអាចបង្កទុក្ខទោសដល់អ្នកដទៃ។ អាជ្ញាធរក៏ត្រូវហាមឃាត់បាតុករមិនឲ្យធ្វើការជ្រៀតជ្រែកដល់សិទ្ធិ ឬសេរីភាពរបស់អ្នកដទៃផងដែរ។ ប្រសិនបើជននោះបដិសេធមិនព្រមប្រគល់ឧបករណ៍ ឬ មិនព្រមឈប់ប្រព្រឹត្តអំពើល្មើសនោះអាជ្ញាធរត្រូវធ្វើការឃាត់ខ្លួនជននោះជាបណ្តោះអាសន្ន។ ប្រសិនបើជននោះមិនបានប្រព្រឹត្តអំពើមិនគប្បីផ្សេងទៀតទេ អាជ្ញាធរត្រូវដោះលែងជននោះភ្លាមក្រោយពីបាតុកម្មបានបញ្ចប់។ ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីបាតុករណាមានកាន់អាវុធ ឬជាតិផ្ទុះ អាជ្ញាធរត្រូវដកហូតអាវុធ ឬជាតិផ្ទុះទាំងនោះ និងត្រូវធ្វើការឃាត់ខ្លួនជននោះ។ (មាត្រា ២៣-២៤)

១-២. ជនណាឆ្លៀតឱកាសក្នុងពេលធ្វើបាតុកម្មដោយសន្តិវិធី ដើម្បីប្រព្រឹត្តអំពើលួច ប្លន់ ឬបង្កឱ្យកើតមានអន្តរាយដល់ទ្រព្យសម្បត្តិ ត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។ (មាត្រា ២៥)

១-៣. ប្រសិនបើដំណើរការ នៃការធ្វើបាតុកម្ម បង្កជាអំពើហិង្សាបណ្តាលឱ្យអន្តរាយដល់ទ្រព្យសម្បត្តិ ជនល្មើសនិងអ្នកសមគំនិតត្រូវមានកាតព្វកិច្ចជួសជុលការខូចខាត។ ក្នុងករណីអ្នកទាំងនោះមិនមានលទ្ធភាពធ្វើការជួសជុលការខូចខាត បញ្ហានេះគួរបញ្ជូនទៅតុលាការ។ (មាត្រា ២៦)

១-៤.	បើបាតុកម្មបង្កជាអំពើហិង្សា ជនណាដែលបានប្រព្រឹត្តល្មើសបណ្ដាលឱ្យអាជ្ញាធរ ឬ បាតុករដទៃទៀតមានរបួសនឹងត្រូវផ្ដន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។ (មាត្រា ២៧)

១-៥. ***ចំណុចបំភ្លឺ៖***

១-៥-១. *ប្រសិនបើអាជ្ញាធរមានសមត្ថកិច្ច រកឃើញថា អ្នកដឹកនាំបាតុកម្ម មិនមានការជាប់ពាក់ព័ន្ធក្នុងបទល្មើសដែលត្រូវបានប្រព្រឹត្តអំឡុងពេលបាតុកម្មទេ នោះពួកគេពុំត្រូវមានការទទួលខុសត្រូវឡើយ។*